00747865

E116/1/2/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Oct-2011, 15:24
CMS/CFO: Kauv Keoratanak

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(០៨)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(08)

ចំពោះមុខ: ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Motoo NOGUCHI
ចៅក្រម សោម សិរីវុឌ្ឍ
ចៅក្រម Agnieszka KLONOWIECKA-MILART
ចៅក្រម ស៊ិន រិទ្ធី
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទ: ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១
ភាសាដើម: អង់គ្លេស/ខ្មែរ
ចំណាត់ថ្នាក់ឯកសារ: សម្ងាត់

សាធារណៈ / Public
31/01/2012

---

# សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលដើម្បីធ្វើសារណាតបទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទ នួន ជា តាមវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង

---

**សហព្រះរាជអាជ្ញា:**
ជា លាង
Andrew CAYLEY

**មេធាវីជនជាប់ចោទ:**
សុន អរុណ
Michiel PESTMAN
Victor KOPPE

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

| | |
|---|---|
| **ជនជាប់ចោទ៖** | អាង ឧត្តម |
| នួន ជា | Michael G. KARNAVAS |
| អៀង សារី | ផាត់ ពៅស៊ាង |
| អៀង ធីរិទ្ធ | Diana ELLIS |
| ខៀវ សំផន | សរ សុវាន |
| | Jacques VERGÈS |

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) ទទួលបានសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេល(“សំណើសុំ”)ដើម្បីដាក់សារណាតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ នួន ជា ដោយអនុលោមតាមវិធាន៣៥នៃវិធានផ្ទៃក្នុង សុំឲ្យបំពេញកិច្ចស៊ើបសួរអំពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ (“សំណើសុំតាមវិធាន ៣៥”)[១]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញ “សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92)” (“សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង”) ដែលមានរួមបញ្ចូលផងដែរនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើសុំតាមវិធាន ៣៥ របស់ជនជាប់ចោទ នួន ជា[២]។ ជនជាប់ចោទ នួន ជា បានប្តឹងសាទុក្ខមកអង្គជំនុំជម្រះតុលាការកំពូលជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុច ដែលអង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំតាមវិធាន៣៥របស់ខ្លួន (“បណ្តឹងសាទុក្ខភ្លាមៗ”)[៣]។

២. នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ឯកសារជាភាសាអង់គ្លេសនៃបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ត្រូវបានជូនដំណឹងដល់ភាគីនានា។ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់សំណើនេះឡើងដើម្បីស្នើសុំពន្យារពេល២០ថ្ងៃនៃប្រតិទិន រហូតដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១១ ក្នុងការដាក់សារណាតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា។

## II. ផ្នែកសំអាងហេតុ

### ក. ច្បាប់ជាធរមាន

៣. វិធាន ៣៩(៤)(ក) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៨) ចែងដូចខាងក្រោម៖

តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត ឬ

[១] សំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលកំណត់ដើម្បីឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ជំទាស់នឹងសេចក្តី-សម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E116/1/2។

[២] ឯកសារ E116។

[៣] បណ្តឹងសាទុក្ខភ្លាមៗ ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E116/1/1។

អង្គជំនុំជម្រះអាច:

ក-ពន្យាពេលវេលាកំណត់ ដែលខ្លួនបានកំណត់...

៤. មាត្រាពាក់ព័ន្ធមួយចំនួននៃសេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក (វិសោធនកម្ម លើកទី៧) ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ") ចែងដូចខាងក្រោម:

លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ឬសេចក្តីណែនាំអនុវត្តនេះ ឬបទបញ្ជាពីអង្គជំនុំជម្រះនៃ អ.វ.ត.ក សារណា និងពាក្យស្នើសុំ ត្រូវដាក់ទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះដែលត្រូវធ្វើចំណាត់ការ ជាមួយនឹងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ដែលប្រើប្រាស់ជាឯកសារយោង អនុលោមទៅតាមពេលវេលាកំណត់ដូចខាងក្រោម ហើយត្រូវបានបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន ៣៩ នៃវិធានផ្ទៃក្នុង ប្រសិនបើមានការស្នើសុំពន្យារពេលកំណត់។

សារណាតបណាមួយទៅនឹងពាក្យសុំ ឬសារណា ត្រូវដាក់រួមជាមួយបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ដែលប្រើប្រាស់ជាឯកសារយោងក្នុងរយៈពេល ១០(ដប់ថ្ងៃ) ថ្ងៃនៃប្រតិទិន គិតពីថ្ងៃជូនដំណឹងនៃឯកសារដែលត្រូវបានឆ្លើយតប។

លើកលែងតែមានការណែនាំផ្ទុយពីនេះរបស់សហចៅក្រមស៊ើបអង្កេត ឬពីអង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក ពេលវេលាកំណត់ត្រូវចាប់ផ្តើមគិតពីថ្ងៃបន្ទាប់នៃថ្ងៃជូនដំណឹងអំពីឯកសារជាភាសាខ្មែរ និងភាសាផ្លូវការណាមួយផ្សេងទៀតរបស់ អ.វ.ត.ក។ ក្នុងករណីពិសេស សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចសម្រេចថា ពេលវេលាកំណត់ត្រូវចាប់ផ្តើមគិតពីថ្ងៃបន្ទាប់នៃថ្ងៃដាក់ឯកសារជាបីភាសាផ្លូវការ[៤]។

## ខ. អង្គសេចក្តី

៥. សហព្រះរាជអាជ្ញាលើកឡើងថា ខ្លួនត្រូវការរយៈពេល២០ថ្ងៃនៃប្រតិទិនបន្ថែមទៀត គឺគិតរហូតដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១១ ដើម្បីរៀបចំ "សារណាតបមួយដោយមានសំអាងហេតុដ៏ល្អ និងយ៉ាងទូលំទូលាយចំពោះបញ្ហានានាខាងអង្គហេតុ និងខាងអង្គច្បាប់ដ៏ស្មុគ្រស្មាញ" នៅក្នុងបណ្តឹងសាទុក្ខភ្លាមៗដែល "មានដាក់បញ្ចូលនូវការយោងទៅលើបញ្ហាទាំងឡាយខាងអង្គហេតុដែលមាននៅក្នុង សំណើ ពាក្យសុំ

[៤] អ.វ.ត.ក/០១/២០០៧/វិ.០៧ មាត្រា ៨.១, ៨.៣, ៨.៥។

ការជំទាស់ និងបណ្តឹងឧទ្ធរណ៍ ជាបន្តបន្ទាប់ ដែលបានដាក់ក្នុងចន្លោះខែមីនា ឆ្នាំ២០០៩ និង ខែមេសា ឆ្នាំ២០១១...។ តាមធម្មតា មិនមានភាពប្រាកដប្រជាទេសម្រាប់ការធ្វើសារណាតប ក្នុងរយៈពេលចំនួន ១០ថ្ងៃ ដោយរួមទាំងពេលវេលាបកប្រែភាសាផងនោះ" [៥]។

៦. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភាពស្មុគស្មាញនៃបញ្ហាអង្គច្បាប់ និងបញ្ហាអង្គហេតុនានា ដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខភ្លាមៗបង្កើតនូវមូលហេតុដ៏ល្អ [៦] ដើម្បីអនុញ្ញាតឲ្យមានការពន្យារពេលដល់ សហព្រះរាជអាជ្ញាក្នុងការដាក់សារណាតប។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សហព្រះរាជអាជ្ញាមិនបានធ្វើយុត្តិកម្មលើសំណើរបស់ខ្លួន សុំបន្ថែមរយៈពេល២០ថ្ងៃនៃប្រតិទិនទៀតនោះទេ ប្រសិនបើអនុញ្ញាតនោះ នឹងអាចនាំឲ្យមានការកំណត់ពេលវេលាមួយសម្រាប់សារណាតបរបស់សហព្រះរាជអាជ្ញា ដែលមានរយៈពេលវែងជាងបីដងនៃរយៈពេលដែលមានកំណត់ នៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ សម្រាប់ភាគីធ្វើសារណាតបនានា រួមទាំងភាគីធ្វើសារណាតបណា ដែលមិនមានមធ្យោបាយគាំទ្រជាផ្លូវការគ្រប់គ្រាន់។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលយល់ថា សហព្រះរាជអាជ្ញាធ្លាប់ជួបប្រទះរួចហើយនូវបញ្ហាស្មុគស្មាញនានា ដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខភ្លាមៗដោយសារការចូលរួមរបស់ខ្លួន ក្នុងនាមជាភាគីមួយនៅក្នុង "ដំណើររឿង នៃសំណើពាក្យសុំ ការជំទាស់ និងបណ្តឹងឧទ្ធរណ៍ជាបន្តបន្ទាប់ ដែលបានដាក់ក្នុងចន្លោះខែមីនា ឆ្នាំ២០០៩ និងខែមេសា ឆ្នាំ២០១១"។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចអនុញ្ញាតពន្យារពេលវេលាកំណត់រយៈពេល ៥ថ្ងៃនៃប្រតិទិនបន្ថែមទៀត ដល់សហព្រះរាជអាជ្ញាដើម្បីដាក់សារណាតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗ ជាភាសាខ្មែរ និងជាភាសាអង់គ្លេស ឬ ភាសាបារាំង។ ជាលទ្ធផលនៃសេចក្តីសម្រេចនេះ សហព្រះរាជអាជ្ញាមានរយៈពេល១៥ ថ្ងៃនៃប្រតិទិន ដើម្បីដាក់សារណាតបរបស់ខ្លួន។

៧. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា អនុលោមតាមមាត្រា៨.៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ វិធានទូទៅចែងថា ពេលវេលាកំណត់សម្រាប់ការដាក់សារណា "ត្រូវចាប់ផ្តើមគិតពីថ្ងៃបន្ទាប់នៃថ្ងៃជូនដំណឹងអំពីឯកសារជាភាសាខ្មែរ និងភាសាផ្លូវការណាមួយផ្សេងទៀតរបស់ អ.វ.ត.ក"។ បណ្តឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទ នួន ជា ត្រូវបានជូនដំណឹងលើកដំបូងជាភាសាអង់គ្លេស នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ហើយនៅថ្ងៃចេញសេចក្តីសម្រេចនេះ ឯកសារបកប្រែជាភាសាខ្មែរ

---

[៥] សំណើ កថាខណ្ឌ ២។

[៦] តុលាការព្រហ្មទណ្ឌអន្តរជាតិ វិធានរបស់តុលាការ ICC-BD/01-02-07 ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៤ (កែសម្រួល) វិធាន ៣៥(២) ("អង្គជំនុំជម្រះអាចពន្យារ ឬកាត់បន្ថយពេលកំណត់ ប្រសិនបើមានការបង្ហាញនូវមូលហេតុត្រឹមត្រូវ និង ក្នុងករណីចាំបាច់ បន្ទាប់ពីបានផ្តល់ឱកាសឲ្យអ្នកចូលរួមធ្វើការបំភ្លឺរួចមក . . .")។

នៃបណ្តឹងសាទុក្ខភ្លាមៗ មិនទាន់ត្រូវបានជូនដំណឹងដល់ភាគីនានានៅឡើយទេ។ ហេតុដូច្នេះ ការកំណត់រយៈពេល១៥ ថ្ងៃសម្រាប់សហព្រះរាជអាជ្ញាក្នុងការដាក់សារណាតប ត្រូវគិតចាប់មួយថ្ងៃបន្ទាប់ពីថ្ងៃជូនដំណឹងអំពីបណ្តឹងសាទុក្ខភ្លាមៗជាភាសាខ្មែរនេះតទៅ។

## III. ផ្នែកសម្រេចសេចក្តី

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេច:**

យល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញា ដោយអនុញ្ញាតឲ្យដាក់សារណាតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗជាភាសាខ្មែរ និងជាភាសាអង់គ្លេស ឬភាសាបារាំង នៅក្នុងរយៈពេល១៥ថ្ងៃនៃប្រតិទិន ដែលត្រូវចាប់ផ្តើមគិតមួយថ្ងៃបន្ទាប់ពីថ្ងៃជូនដំណឹងអំពីបណ្តឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទ **នួន ជា** ជាភាសាខ្មែរ។

ភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១

ជ. ប្រធានអង្គជំនុំជម្រះតុលាការកំពូល

SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C * C.E.T.C

មុំ មុន្នីចរិយា